**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកៅស៊ូ**

លេខ: ១១៣ អក.ស៊

ថ្ងៃ......................ខែ..............ឆ្នាំ..........ស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី.....២៥.....ខែ.....មករា.....ឆ្នាំ២០២១

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្ដីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមករា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់** ៖ -របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមករា ឆ្នាំ២០២១..........ចំនួន០១ច្បាប់

-តារាងស្ថានភាពផលិតកម្មកៅស៊ូ និងតារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូ ប្រចាំខែមករាឆ្នាំ២០២១ ..............................................................ចំនួន០២ច្បាប់។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមករា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តសម្រាប់ចុះក្នុងរបាយការណ៍របស់ក្រសួងក្នុងខែកុម្ភៈដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៤ ១១៨ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៩២ ៤៩៧ហិកតា ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន១១១ ៦២១ហិកតា ស្មើនឹង២៨%។

២-ផលិតផលជ័រកៅស៊ូក្នុងខែមានចំនួន៣២ ៨៤៣តោន កើនឡើងចំនួន៣ ៦៤០តោន ស្មើនឹង១២% ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់ក្នុងខែមានចំនួន៣០ ៩០៩តោន បានកើនឡើងចំនួន៣ ៤០២តោន ស្មើនឹង១២%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែថ្លៃ១ ៥៥៧ដុល្លារ/តោន បានកើនឡើងចំនួន១២៩ដុល្លារ/តោនស្មើនឹង៩%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

៥-តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៥ ៥៧៥-៥ ៨០០៛/គ.ក្រ(បានកើនឡើងចំនួន៩១៛/គ.ក្រ ធៀបនឹងខែមុនឆ្នាំ២០២០) និងជ័រកក (DRC 50%) ថ្លៃ២ ១៥០-២ ៧៥០៛/គ.ក្រ បានថយចុះចំនួន១៥៥៛/គ.ក្រ ធៀបនឹងខែមុនឆ្នាំ២០២០) អាស្រ័យតាមតំបន់។

៦-ទិសដៅបន្ត៖ ខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

"ដើម្បីជ្រាប"

- ឯកសារ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍សរុប
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែមករា ឆ្នាំ ២០២១ និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២១នេះ អគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងឆ្នាំ២០២១ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៤ ១១៨ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៩២ ៤៩៧ហិកតា ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន១១១ ៦២១ហិកតា ស្មើនឹង២៨%។

#### ២.១.២ ផលិតកម្ម

ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែមករា ឆ្នាំ២០២១ មានចំនួន៣២ ៨៤៣តោន បានកើនឡើងចំនួន៣ ៦៤០តោនស្មើនឹង១២%ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំមុន។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែមករា ឆ្នាំ២០២១ មានចំនួន៣០ ៩០៩តោន បានកើនឡើងចំនួន៣ ៤០២តោន ស្មើនឹង១២%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែមករា ឆ្នាំ២០២១ គឺ១ ៥៥៧ដុល្លារ/តោន បានកើនឡើងចំនួន១២៩ដុល្លារ/តោន ស្មើនឹង៩%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៥ ៥៧៥-៥ ៨០០ រ/គ.ក្រ(បានកើនឡើងចំនួន៩១រ/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ២ ១៥០-២ ៧៥០រ/គ.ក្រ បានថយចុះចំនួន១៥៥រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

### ២.២. ការងារចរន្ត និងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

#### ២.២.១. ការងារចរន្ត

- ចូលរួមកែសម្រួល ចំណុចមួយចំនួនពាក់ព័ន្ធនិងការបង្កើតគេហទំព័ររបស់អគ្គនាយកដ្ឋានកៅស៊ូ
- តាមដាន ករណីទំនាស់ពាក់ព័ន្ធនិងបណ្តាលក្រុមហ៊ុនចម្ការកៅស៊ូ

- បានចុះបេសកកម្ម សហការជាមួយអង្គការ WWF បើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគីរី
- បានចុះបេសកកម្មពិនិត្យ និងពិភាក្សាការរៀបចំចម្ការបង្ហាញលើការអនុវត្តបច្ចេកទេស GAP និងការកែលម្អប្រព័ន្ធចៀជ័រ នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី
- កិច្ចប្រជុំជាមួយអង្គការ OXFAM ដើម្បីពិភាក្សាលើសកម្មភាពសម្រាប់កិច្ចសហប្រត្តិបត្តិការអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជាប្រកបដោយនិរន្តភាព
- រៀបចំ Power Point ស្តីពីបច្ចេកទេសដំណាំកៅស៊ូ សម្រាប់សកម្មភាពចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី
- ចូលរួមពិនិត្យកែសម្រួលលើអត្ថបទ "ឥទ្ធិពលនៃការចៀរជ័រដើមកៅស៊ូទំហំតូចលើផលិតកម្មកៅស៊ូ" សម្រាប់ដាក់ចូលក្នុងព្រឹត្តិបត្រកៅស៊ូធម្មជាតិ របស់អគ្គនាយកដ្ឋានកៅស៊ូ
- ចុះបំពេញបេសកកម្ម ដោយសហការជាមួយអង្គការមូលនិធិសកលសម្រាប់ធម្មជាតិ(WWF)ប្រចាំព្រះរាជាណាចក្រកម្ពុជា ទៅតាមបណ្តាលភូមិចំនួន១០ ស្ថិតក្នុងស្រុកពេជ្រាដា ដើម្បីបើកវគ្គផ្សព្វផ្សាយ ការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងការព្យាបាលជម្ងឺលើដើមកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- បានធ្វើរបាយការណ៍ចំណូល ចំណាយថវិការជ្ជប្រចាំឆ្នាំ២០២០
- បានធ្វើផែនការថវិការជ្ជទេយ្យបុរេប្រទាន ឆ្នាំ២០២១
- បានបញ្ចូលរបាយការណ៍តាមដាននិងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០២០(ទម្រង់M1&M2) របស់អគ្គនាយកដ្ឋានកៅស៊ូ ទៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- បានប្រជុំពិនិត្យកែសម្រួលសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកៅស៊ូ
- បន្តតាមដានការបង់ថ្លៃឈ្នួលដីអវិនិយោគចម្ការកៅស៊ូទាំង៧ ក្រុមហ៊ុនចម្ការកៅស៊ូឡាបានសៀក និងក្រុមហ៊ុននីហរ័ណ អាហរ័ណកៅស៊ូ
- ប្រជុំពិនិត្យសម្រេចលើខ្លឹមសារឯកសារធាតុចូលរបស់នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ និងរចនាបទគេហទំព័ររបស់អគ្គនាយកដ្ឋានកៅស៊ូ
- តាមដានត្រួតពិនិត្យ ស្រាវជ្រាវអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅស្រុក ប្រមូល និងចងក្រងទិន្នន័យថ្លៃទិញ លក់កៅស៊ូធម្មជាតិ ប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ស្តីពីធុរៈកិច្ចផលិតផលកៅស៊ូធម្មជាតិប្រចាំខែ
- សិក្សាស្រាវជ្រាវផ្សព្វផ្សាយព័ត៌មានអំពីពន្ធនាំចេញកៅស៊ូ
- សិក្សាស្រាវជ្រាវលើការនាំចេញផលិតផលជ័រនិងឈើកៅស៊ូ
- ផ្សព្វផ្សាយអំពីច្បាប់ លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធការនាំចេញផលិតផលជ័រនិងឈើកៅស៊ូ
- រៀបចំលិខិតឆ្លើយតប ដែលពាក់ព័ន្ធនឹងការងារសហប្រតិបត្តិការអន្តរជាតិ ទៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

**២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី**

ការចំណាយថវិកាតាមគម្រោងកម្មវិធីក្នុងខែមករា ឆ្នាំ២០២១ គឺមិនមាន។

**២.២.៣. ការប្រមូលចំណូលថវិកា**

ការបង់ថ្លៃឈ្នួលដីអវិនិយោគក្នុងខែមករា ឆ្នាំ២០២១គឺមិនមាន។

**៣. ទិសដៅបន្ត**

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ
- បន្តតាមដាន ករណីទំនាស់ពាក់ព័ន្ធនិងបណ្តាលក្រុមហ៊ុនចម្ការកៅស៊ូ
- ចុះសម្របសម្រួលរៀបចំសិក្ខាសាលាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចជាមួយអង្គការ OXFAM
- បន្តសហការជាមួយអង្គការ WWF រៀបចំវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ រៀបចំ Leaflates, រៀបចំ Demo, រៀបចំ Video បច្ចេកទេស និងពង្រឹងសហគមន៍នៅខេត្តមណ្ឌលគីរី
- បន្តចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- បន្តចុះពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- ត្រៀមអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- ត្រៀមរៀបចំប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅអនុវត្តឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកៅស៊ូ
- បន្តខិតខំផ្សព្វផ្សាយតម្លៃជ័រកៅស៊ូធម្មជាតិ នៅលើទីផ្សារក្នុងស្រុកនិងអន្តរជាតិតាមបណ្តាញសង្គម (ហ្វេសប៊ុក)ឲ្យបានដល់កសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូ
- បន្តសិក្សាស្រាវជ្រាវផ្សព្វផ្សាយពត៌មានអំពីការផ្គត់ផ្គង់ តម្រូវការ ការប្រើប្រាស់កៅស៊ូធម្មជាតិនិងនិន្នាការតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ
- បន្តតាមដានលើវឌ្ឍនភាព នៃកិច្ចសហប្រត្តិបត្តិការជាមួយបណ្តាប្រទេសជាដៃគូរ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូបានប្រគល់អោយ។

**បានឃើញនិងឯកភាព**

**ឧ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**អគ្គនាយករង**

យុន ភក្តដា

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២១

**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

យួន_ផល្លា

**អគ្គនាយកដ្ឋានកៅស៊ូ**
**នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែមករា ឆ្នាំ២០២១

**តារាងទី១**

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០២០ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២១ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចៀរជ័រ | ថែទាំ | សរុប | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | | | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | | | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 520 | 100 | 620 | 35 | 35 | - | - | 487 | 83 | 83 | 35 | 35 | 0 | 0 | 0 | 0 | 0 | 0 | 49 | 140 | 49 | 140 | 35 | 100 | 35 | 100 | 535 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 11.287 | 2.048 | 13.335 | 1.595 | 1.595 | 937 | 937 | 1.766 | 1.944 | 1.944 | 792 | 792 | 0 | 0 | 0 | 0 | 0 | 0 | 349 | 22 | 349 | 22 | -144 | -15 | -144 | -15 | 2.917 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.179 | 1.220 | 2.399 | 157 | 157 | - | - | 176 | 198 | 198 | 210 | 210 | 0 | 0 | 0 | 0 | 0 | 0 | 40 | 26 | 40 | 26 | 210 | 100 | 210 | 100 | 164 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 6.092 | 2.331 | 8.423 | 434 | 434 | 282 | 282 | 550 | 514 | 514 | 282 | 282 | 0 | 0 | 0 | 0 | 0 | 0 | 80 | 18 | 80 | 18 | 0 | 0 | 0 | 0 | 782 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់បើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | 32 | 32 | 62 | 62 | 68 | 74 | 74 | - | - | 0 | 0 | 0 | 0 | 0 | 0 | 42 | 129 | 42 | 129 | -62 | 0 | -62 | 0 | 142 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វីសសស៍ លីមីធីត(ស្នួល) | 4.174 | 76 | 4.250 | 376 | 376 | 432 | 432 | 1.608 | 607 | 607 | 1.159 | 1.159 | 0 | 0 | 0 | 0 | 0 | 0 | 231 | 62 | 231 | 62 | 727 | 168 | 727 | 168 | 1.056 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 3.908 | 278 | 4.186 | 380 | 380 | 525 | 525 | 976 | 236 | 236 | 210 | 210 | 0 | 0 | 0 | 0 | 0 | 0 | -145 | -38 | -145 | -38 | -315 | -60 | -315 | -60 | 1.002 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 3.312 | 1.570 | 4.882 | 110 | 110 | 230 | 230 | 672 | 99 | 99 | 130 | 130 | 0 | 0 | 0 | 0 | 0 | 0 | -11 | -10 | -11 | -10 | -100 | -43 | -100 | -43 | 641 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+រមាសហែក) | 1.918 | 1.119 | 3.037 | 83 | 83 | 129 | 129 | 477 | 71 | 71 | 70 | 70 | 0 | 0 | 0 | 0 | 0 | 0 | -12 | -15 | -12 | -15 | -59 | -46 | -59 | -46 | 478 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4.097 | 701 | 4.798 | 599 | 599 | 210 | 210 | 1.234 | 517 | 517 | 420 | 420 | 0 | 0 | 0 | 0 | 0 | 0 | -82 | -14 | -82 | -14 | 210 | 100 | 210 | 100 | 1.331 |
| | **សរុប ក** | 36.794 | 11.861 | 48.655 | 3.803 | 3.803 | 2.807 | 2.807 | 8.014 | 4.343 | 4.343 | 3.309 | 3.309 | 0 | 0 | 0 | 0 | 0 | 0 | 540 | 14 | 540 | 14 | 502 | 18 | 502 | 18 | 9.049 |
| ខ | **ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច** | 105.953 | 88.350 | 194.303 | 10.600 | 10.600 | 10.200 | 10.200 | 11.283 | 13.200 | 13.200 | 12.800 | 12.800 | 0 | 0 | 0 | 0 | 0 | 0 | 2.600 | 25 | 2.600 | 25 | 2.600 | 25 | 2.600 | 25 | 11.683 |
| | **សរុបI=ក+ខ** | 142.747 | 100.211 | 242.958 | 14.403 | 14.403 | 13.007 | 13.007 | 19.297 | 17.543 | 17.543 | 16.109 | 16.109 | 0 | 0 | 0 | 0 | 0 | 0 | 3.140 | 22 | 3.140 | 22 | 3.102 | 24 | 3.102 | 24 | 20.732 |
| | **II. កៅស៊ូគ្រួសារ** | 149.750 | 11.410 | 161.160 | 14.800 | 14.800 | 14.500 | 14.500 | 10.900 | 15.300 | 15.300 | 14.800 | 14.800 | 0 | 0 | 0 | 0 | 0 | 0 | 500 | 3 | 500 | 3 | 300 | 2 | 300 | 2 | 11.400 |
| | **សរុបរួមI+II** | 292.497 | 111.621 | 404.118 | 29.203 | 29.203 | 27.507 | 27.507 | 30.197 | 32.843 | 32.843 | 30.909 | 30.909 | 0 | 0 | 0 | 0 | 0 | 0 | 3.640 | 12 | 3.640 | 12 | 3.402 | 12 | 3.402 | 12 | 32.132 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន ៤០៤ ១១៨ ហត ( ផ្ទៃដីចៀរជ័រ ២៩២ ៤៩៧ ហត ថែទាំ ១១១ ៦២១ហត) ។

(២) ផលិតផលសរុបចំនួន៣២ ៨៤៣ តោន បានកើនឡើងចំនួន៣ ៦៤០ តោន (១២%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

(៣) ការបញ្ចេញលក់សរុបចំនួន៣០ ៩០៩តោន បានកើនឡើងចំនួន៣ ៤០២ តោន (១២%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

(៤) សន្និធិចុងគ្រាមានចំនួន៣២ ១៣២ តោន

**បានឃើញ និងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

ឃុន ភក្ដា

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

ឃួន_ផល្លា

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១
អ្នកធ្វើតារាង

[illegible]

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារតាមតំបន់

*ខែមករា ឆ្នាំ២០២១*

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | ថ្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | ៛/គ.ក្រ |
| ១ | ត្បូងឃ្មុំ | 5.800 | 1,43 | → 0 | 2.300 | 0,57 | → 0 | 5.800 | 1,43 | → 0 | 2.300 | 0,57 | → 0 | 5.800 | 1,43 | → 0 | 2.300 | 0,57 | → 0 | 5.800 | 1,43 | → 0 | 2.300 | 0,57 | → 0 | 5.800 | 2.300 |
| ២ | ក្រចេះ | 5.800 | 1,43 | → 0 | 2.550 | 0,63 | → 0 | 5.800 | 1,43 | → 0 | 2.550 | 0,63 | → 0 | 5.800 | 1,43 | → 0 | 2.550 | 0,63 | → 0 | 5.800 | 1,43 | → 0 | 2.550 | 0,63 | → 0 | 5.800 | 2.550 |
| ៣ | កំពង់ធំ | 5.800 | 1,43 | → 0 | 2.200 | 0,54 | → 0 | 5.800 | 1,43 | → 0 | 2.200 | 0,54 | → 0 | 5.800 | 1,43 | → 0 | 2.200 | 0,54 | → 0 | 5.800 | 1,43 | → 0 | 2.200 | 0,54 | → 0 | 5.800 | 2.200 |
| ៤ | កំពង់ចាម | 5.800 | 1,43 | → 0 | 2.300 | 0,57 | → 0 | 5.800 | 1,43 | → 0 | 2.300 | 0,57 | → 0 | 5.800 | 1,43 | → 0 | 2.200 | 0,54 | ↓ 100 | 5.800 | 1,43 | → 0 | 2.200 | 0,54 | → 0 | 5.800 | 2.250 |
| ៥ | រតនគិរី | 5.600 | 1,38 | → 0 | 2.600 | 0,64 | → 0 | 5.800 | 1,43 | ↑ 200 | 2.800 | 0,69 | ↑ 200 | 5.800 | 1,43 | → 0 | 2.800 | 0,69 | → 0 | 5.800 | 1,43 | → 0 | 2.600 | 0,64 | ↓ 200 | 5.750 | 2.700 |
| ៦ | ស្ទឹងត្រែង | 5.500 | 1,36 | → 0 | 2.550 | 0,63 | → 0 | 5.500 | 1,36 | → 0 | 2.650 | 0,65 | ↑ 100 | 5.500 | 1,35 | → 0 | 2.650 | 0,65 | → 0 | 5.800 | 1,43 | ↑ 300 | 2.700 | 0,66 | ↑ 50 | 5.575 | 2.638 |
| ៧ | ព្រះវិហារ | 5.800 | 1,43 | → 0 | 2.600 | 0,64 | → 0 | 5.800 | 1,43 | → 0 | 2.600 | 0,64 | → 0 | 5.800 | 1,43 | → 0 | 2.600 | 0,64 | → 0 | 5.800 | 1,43 | → 0 | 2.600 | 0,64 | → 0 | 5.800 | 2.600 |
| ៨ | ឧត្តរមានជ័យ | | | | 2.300 | 0,57 | → 0 | | | | 2.400 | 0,59 | ↑ 100 | | | | 2.400 | 0,59 | → 0 | | | | 2.400 | 0,59 | → 0 | | 2.375 |
| ៩ | មណ្ឌលគិរី | | | | 2.550 | 0,63 | → 0 | | | | 2.550 | 0,63 | → 0 | | | | 2.550 | 0,63 | → 0 | | | | 2.550 | 0,63 | → 0 | | 2.550 |
| ១០ | ពោធិ៍សាត់ | | | | 2.200 | 0,54 | → 0 | | | | 2.200 | 0,54 | → 0 | | | | 2.300 | 0,57 | ↑ 100 | | | | 2.300 | 0,57 | → 0 | | 2.250 |
| ១១ | កំពត | | | | 2.150 | 0,53 | → 0 | | | | 2.150 | 0,53 | → 0 | | | | 2.150 | 0,53 | → 0 | | | | 2.150 | 0,53 | → 0 | | 2.150 |
| ១២ | ប៉ៃលិន | | | | 2.800 | 0,69 | → 0 | | | | 2.800 | 0,69 | → 0 | | | | 2.700 | 0,67 | ↓ 100 | | | | 2.700 | 0,66 | → 0 | | 2.750 |
| | ថ្លៃមធ្យម | 5.729 | 1,41 | ↑ 5.727 | 2.425 | 0,60 | ↑ 2.424 | 5.757 | 1,42 | ↑ 29 | 2.458 | 0,61 | ↑ 33 | 5.757 | 1,42 | → 0 | 2.450 | 0,60 | ↓ 8 | 5.800 | 1,43 | ↑ 43 | 2.438 | 0,60 | ↓ 13 | 5.761 | 2.443 |
| | អត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជា | | 4.050 | | | | | | 4.053 | | | | | | 4.060 | | | | | | 4.065 | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | $ 1,44 | $ 0,61 |

បញ្ជាក់៖

*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*

*ទឹកជ័រ: គិតជាស្ងួត (DRC)*

*ជ័រកក: DRC ≅ 50%*

ក្នុងខែមករា ឆ្នាំ២០២១ ថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមតំបនិ គឺទឹកជ័រ(DRC 100%) ថ្លៃ៥៥៧៥៛-៥៨០០៛/គ.ក្រ (បានកើនឡើង ៩១៛/គ.ក្រ ធៀបខែមុនឆ្នាំ២០២០) និងជ័រកក(DRC 50%) ថ្លៃ២១៥០-២៧៥០៛/គ.ក្រ (ថយចុះ១៥៥៛/គ.ក្រ ធៀបខែមុនឆ្នាំ២០២០) អាស្រ័យតាមតំបន់។

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

យុន កក្កដា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន

ថ្ងៃ ... ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ កុម្ភៈ ឆ្នាំ២០២១
អ្នកធ្វើតារាង

**អគ្គនាយកដ្ឋានគៅស៊ូ**
**នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែមករា ឆ្នាំ២០២១

**តារាងទី២**

| ល.រ | ចម្ការកៅស៊ូ | មករា ២០២០ | | | | | | មករា ២០២១ | | | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | ថ្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | ថ្លៃមធ្យម($/តោន) | | បរិមាណ | | | | ថ្លៃមធ្យម | | | |
| | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | តោន | % | $/តោន | % | $/តោន | % |
| I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | | 0 | | 0 | 0 | 0 | 35 | 35 | 43.400 | 43.400 | 1.240 | 1.240 | 35 | 100 | 35 | 100 | 1.240 | 100 | 1.240 | 100 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 937 | 937 | 1.373.716 | 1.373.716 | 1.466 | 1.466 | 792 | 792 | 1.528.780 | 1.528.780 | 1.929 | 1.929 | 1.929 | -15 | 1.929 | -15 | 463 | 32 | 463 | 32 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | | 0 | | 0 | 0 | 0 | 210 | 210 | 322.770 | 322.770 | 1.537 | 1.537 | 1.537 | 100 | 1.537 | 100 | 1.537 | 100 | 1.537 | 100 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 282 | 282 | 412.070 | 412.070 | 1.460 | 1.460 | 282 | 282 | 412.070 | 412.070 | 1.460 | 1.460 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់បើ លីមីតធីត(រតនគិរី) | 62 | 62 | 73.779 | 73.779 | 1.190 | 1.190 | | 0 | | 0 | 0 | 0 | -62 | 0 | -62 | 0 | -1.190 | 0 | -1.190 | 0 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វីសសស់ លីមីធីត(ស្នួល) | 432 | 432 | 604.800 | 604.800 | 1.400 | 1.400 | 1.159 | 1.159 | 1.716.740 | 1.716.740 | 1.481 | 1.481 | 727 | 168 | 727 | 168 | 81 | 6 | 81 | 6 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 525 | 525 | 781.725 | 781.725 | 1.489 | 1.489 | 210 | 210 | 292.950 | 292.950 | 1.395 | 1.395 | -315 | -60 | -315 | -60 | -94 | -6 | -94 | -6 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 230 | 230 | 286.600 | 286.600 | 1.246 | 1.246 | 130 | 130 | 174.000 | 174.000 | 1.338 | 1.338 | -100 | -43 | -100 | -43 | 92 | 7 | 92 | 7 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 129 | 129 | 158.422 | 158.422 | 1.232 | 1.232 | 70 | 70 | 93.000 | 93.000 | 1.329 | 1.329 | -59 | -46 | -59 | -46 | 97 | 8 | 97 | 8 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 210 | 210 | 315.000 | 315.000 | 1.500 | 1.500 | 420 | 420 | 567.000 | 567.000 | 1.350 | 1.350 | 210 | 100 | 210 | 100 | -150 | -10 | -150 | -10 |
| សរុប ក | | 2.807 | 2.807 | 4.006.113 | 4.006.113 | 1.427 | 1.427 | 3.309 | 3.309 | 5.150.711 | 5.150.711 | 1.557 | 1.557 | 502 | 18 | 502 | 18 | 129 | 9 | 129 | 9 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 10.200 | 10.200 | 14.559.170 | 14.559.170 | 1.427 | 1.427 | 12.800 | 12.800 | 19.925.862 | 19.925.862 | 1.557 | 1.557 | 2.600 | 25 | 2.600 | 25 | 129 | 9 | 129 | 9 |
| សរុបI=ក+ខ | | 13.007 | 13.007 | 18.565.282 | 18.565.282 | 1.427 | 1.427 | 16.109 | 16.109 | 25.076.573 | 25.076.573 | 1.557 | 1.557 | 3.102 | 24 | 3.102 | 24 | 129 | 9 | 129 | 9 |
| II. កៅស៊ូគ្រួសារ | | 14.500 | 14.500 | 20.696.859 | 20.696.859 | 1.427 | 1.427 | 14.800 | 14.800 | 23.039.278 | 23.039.278 | 1.557 | 1.557 | 300 | 2 | 300 | 2 | 129 | 9 | 129 | 9 |
| សរុបI+II | | 27.507 | 27.507 | 39.262.141 | 39.262.141 | 1.427 | 1.427 | 30.909 | 30.909 | 48.115.852 | 48.115.852 | 1.557 | 1.557 | 3.402 | 12 | 3.402 | 12 | 129 | 9 | 129 | 9 |

**បញ្ជាក់៖**

១. ក្នុងខែមករា ឆ្នាំ២០២១ បរិមាណបញ្ចេញលក់សរុបមានចំនួន៣០ ៩០៩តោន បានកើនឡើងចំនួន៣ ៤០២តោន(=+១២%)បើធៀបនឹងខែមុន និងបានកើនឡើងចំនួន៣ ៤០២តោន(=+១២%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

២. ថ្លៃលក់មធ្យមក្នុងខែមករា ឆ្នាំ២០២១ គឺ១ ៥៥៧ដុល្លារ/តោន បានកើនឡើងចំនួន១២៩ដុល្លារ/តោន(=+៩%) ធៀបនឹងខែមុន និងបានកើនឡើងចំនួន១២៩ដុល្លារ/តោន (=+៩%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

**បានឃើញ និងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**យុន កក្កដា**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ**

**ហ៊ិន-សាផន**

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១
អ្នកធ្វើតារាង